# សុន្ទរកថា
# ឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី
# តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
# នៃព្រះរាជាណាចក្រកម្ពុជា
# ថ្លែងក្នុងឱកាសប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ ធ្នូ ២០១៨
# ក្រោមប្រធានបទ "យើងប្តេជ្ញារួមគ្នាបញ្ចប់បញ្ហាអេដស៍ នៅឆ្នាំ២០២៥"
# នៅសាលសន្និសីទចតុមុខ, ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៨

- សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ
- ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា រាជរដ្ឋាភិបាល ព្រឹទ្ធសភា និងរដ្ឋសភា
- ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត តំណាងអង្គទូតនានា
- ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ភ្ញៀវជាតិ-អន្តរជាតិ ក្មួយៗនិស្សិត និងសិស្សានុសិស្សទាំងអស់ជាទីរាប់អាន !

១. ថ្ងៃនេះ ខ្ញុំព្រះករុណា ខ្ញុំមានកិត្តិយស និងមានសេចក្តីសោមនស្សរីករាយ ក្នុងនាមជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយបានមកចូលរួមជាមួយឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ នៅក្នុងឱកាសប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ ធ្នូ ២០១៨ ដែលកម្ពុជាចាប់ផ្តើមរៀបចំបានចំនួន ២៥លើករួចមកហើយ ហើយនេះក៏ជាឱកាសមួយដែលអនុញ្ញាតឱ្យរូបខ្ញុំផ្ទាល់បានសម្តែងនូវការកោតសរសើរដ៏ស្មោះ និងវាយតម្លៃខ្ពស់ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនជាសកម្មជនប្រយុទ្ធនឹងជំងឺអេដស៍ជាតិ និងអន្តរជាតិ គ្រប់លំដាប់ថ្នាក់នៅទូទាំងប្រទេស ដែលបានខិតខំប្រឹងប្រែងប្រកបដោយឆន្ទៈមោះមុត ប្តេជ្ញាចិត្តខ្ពស់ធ្វើការប្រយុទ្ធនឹងជំងឺអេដស៍បានទទួលជោគជ័យគួរជាទីមោទនៈ តាមរយៈការកាត់បន្ថយការចម្លងមេរោគអេដស៍ថ្មី កាត់បន្ថយអត្រាមរណភាពដោយសារជំងឺអេដស៍ កាត់បន្ថយអត្រារើសអើងមាក់ងាយលើអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ដែលវឌ្ឍន៍ភាពទាំងអស់នេះពិតជាធ្វើឲ្យទស្សនៈវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជានឹងសម្រេចបាននូវការបញ្ចប់បញ្ហាអេដស៍នៅឆ្នាំ២០២៥ ខាងមុខនេះ។

២. វឌ្ឍនភាព ប្រសិទ្ធភាពនិងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ ដែលកម្ពុជាទទួលបាននាពេលនេះ

គឺជាភ័ស្តុតាងវិទ្យាសាស្ត្របញ្ជាក់យ៉ាងច្បាស់ថា ទស្សនវិស័យរបស់យើងក្នុងការកសាងសង្គមមួយ ដែលគ្មានការគំរាមកំហែងពីមេរោគអេដស៍ និងជំងឺអេដស៍ គឺពិតជាអាចធ្វើបាន ហើយមានន័យថា កម្ពុជាកំពុងតែស្ថិតនៅលើផ្លូវត្រូវ ដែលនឹងឈានទៅសម្រេចបាននូវ “ **គោលដៅ ៩៥ ៩៥ ៩៥** ” ដែលកំណត់ដោយអង្គការសហប្រជាជាតិយ៉ាងពិតប្រាកដ។

៣. ផ្អែកតាមរបាយការណ៍របស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ស្តីពីការងារប្រយុទ្ធទប់ស្កាត់ការរាលដាល និងស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា ឆ្នាំ២០១៨ បង្ហាញថា កម្ពុជាបានកាត់បន្ថយការចម្លងមេរោគអេដស៍ថ្មី រហូតដល់ទៅ៥០% គិតចាប់តាំងពីឆ្នាំ២០១១ មក ។ លើសពីនេះទៅទៀត កម្ពុជាអាចផ្តល់ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ទៅដល់អ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ដែលកំពុងត្រូវការការព្យាបាលបានរហូតដល់ទៅ៩៨% ដែលជាលទ្ធផលធ្វើឱ្យអត្រាមរណភាពដោយសារជំងឺអេដស៍បន្តធ្លាក់ចុះជារៀងរាល់ឆ្នាំនៅកម្ពុជា នេះគឺជាមោទនភាពមួយដែលអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងបណ្តាក្រសួង ស្ថាប័ន និងតួអង្គពាក់ព័ន្ធនានាសហការគ្នាសម្រេចបានក្នុងការងារប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ នៅកម្ពុជា ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី និងក្មួយៗជានីរាប់អាន!**

៤. ទោះបីជាប្រទេសកម្ពុជាយើង បាននិងកំពុងទទួលបានជោគជ័យជាបន្តបន្ទាប់ដ៏គួរឱ្យមោទនពិតមែន តែស្ថានភាពជោគជ័យរបស់យើងនាពេលនេះ នៅមានលក្ខណៈផុយស្រួយនៅឡើយ មានន័យថាប្រសិនបើយើងហ៊ានធ្វេសប្រហែសតែបន្តិច នោះការរាលដាលមេរោគអេដស៍នឹងអាចផ្ទុះឡើងវិញ ដែលអាចនឹងធ្វើឲ្យយើងពិបាកគ្រប់គ្រងជាងពេលមុនៗ ជាពិសេសគឺការផ្ទុះឡើងនៅក្នុងចំណោមក្រុមយុវវ័យ ក្រុមបុរសស្រឡាញ់បុរស ក្រុមអ្នកប្រើប្រាស់ និងចាក់គ្រឿងញៀន ក្រុមប្រជាជនចំណាកស្រុក ក្រុមបុគ្គលិកគ្រឹះស្ថានកម្សាន្តសប្បាយ ។ល។ ដែលយើងនៅមិនទាន់គ្រប់គ្រងបានគ្រប់ជ្រុងជ្រោយនៅឡើយ។ ដូច្នេះ សូមបងប្អូនប្រជាជនទាំងអស់បន្តការយកចិត្តទុកដាក់ខ្ពស់បំផុត ក្នុងការបង្ការខ្លួនជាប់ជានិច្ចពីការចម្លងមេរោគអេដស៍ និងបន្តចូលរួមយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាល ដើម្បីយើងឆ្ពោះទៅបញ្ចប់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ នៅឆ្នាំ ២០២៥។

៥. ដើម្បីគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ ដែលដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជាប្រមុខ និងក្នុងដំណើររបស់ប្រជាជាតិ និងប្រជាជនកម្ពុជាឆ្ពោះ

ទៅមុខប្រកបដោយភាពជឿជាក់នៅលើមាគ៌ានៃការអភិវឌ្ឍ សន្តិភាព និងស្ថិរភាព ក៏ដូចជាការទ្រទ្រង់ដំណើរការវិវឌ្ឍឈានឡើងរបស់កម្ពុជាលើវិថីនៃការអភិវឌ្ឍប្រកបដោយគុណភាព និងចីរភាព រាជរដ្ឋាភិបាលបានកំណត់អាទិភាពគោលនយោបាយសំខាន់ៗ ក្នុងនោះរួមមាន ការអភិវឌ្ឍធនធានមនុស្ស ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ការបន្តអភិវឌ្ឍ និងបង្កើនតម្លៃបន្ថែមនៃវិស័យកសិកម្ម ការលើកកម្ពស់គុណភាពសេវាសុខាភិបាលឲ្យកាន់តែល្អប្រសើរ ការកែលម្អប្រព័ន្ធអប់រំឲ្យកាន់តែមានគុណភាពខ្ពស់ ការលើកកម្ពស់ប្រព័ន្ធគាំពារសង្គម ពិសេសការអនុវត្តកម្មវិធីកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យដែលរាជរដ្ឋាភិបាលបានដាក់ចេញ ដើម្បីបន្តគាំទ្រនិងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយគុណភាព ធានាបានសមធម៌ក្នុងដំណើរឆ្ពោះទៅសម្រេចឲ្យបានចក្ខុវិស័យអភិវឌ្ឍន៍កម្ពុជាជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ ។ ទន្ទឹមនោះ រាជរដ្ឋាភិបាលនឹងបន្តថែរក្សាភាពជោគជ័យរបស់វិស័យសុខាភិបាល លើការកាត់បន្ថយអត្រាមរណភាពមាតា ទារក និងកុមារ កាត់បន្ថយការឈឺនិងស្លាប់ដោយសារជំងឺឆ្លងនានា ដូចជាជំងឺអេដស៍ គ្រុនចាញ់ និងរបេង និងការប្រើប្រាស់និងពង្រឹងមូលនិធិសមធម៌សុខាភិបាល សម្រាប់ប្រជាជនក្រីក្រនិងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ឲ្យកាន់តែទូលំទូលាយជូនប្រជាជនយើង ។

**ឯកឧត្តម លោកជំទាវ និងអង្គពិធី!**

៦. ការប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីឈានទៅសម្រេចបាននូវគោលដៅសូន្យបី នាឆ្នាំ២០២៥ គឺមិនមែនជាការងាយស្រួលនោះទេ តែក៏មិនមែនមានន័យថាយើងធ្វើមិនបាននោះដែរ គ្រាន់តែទាមទារនូវកិច្ចសហការ ការដឹកនាំ ការគ្រប់គ្រង ការសម្របសម្រួល និងការចូលរួមប្រកបដោយការប្តេជ្ញាចិត្តខ្ពស់រួមគ្នា និងជម្នះឱ្យបាននូវរាល់ឧបសគ្គនានា ដែលរារាំងដល់ការធ្វើអន្តរាគមន៍របស់យើងតែប៉ុណ្ណោះ ដូចជាកត្តារើសអើង កត្តាធនធាន កត្តាបច្ចេកវិទ្យា។ល។

៧. ក្នុងនាមជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមប្រកាសជាឱឡារិកថា ព្រះរាជាណាចក្រកម្ពុជា ក្នុងឋានៈជាសមាជិកអង្គការសហប្រជាជាតិ ដែលបានចូលរួមរៀបចំនិងសម្រេចរួចទៅហើយនាមហាសន្និបាតវិសាមញ្ញអង្គការសហប្រជាជាតិ ស្តីពីជំងឺអេដស៍ ឆ្នាំ២០១៦ នៅបុរីញូយ៉ក ក្នុងការដាក់ចេញនូវ “ **សេចក្តីថ្លែងការណ៍ថ្មី ស្តីពីការសម្រេចចិត្តជាននយោបាយ ក្នុងការឈានទៅលុបបំបាត់ជំងឺអេដស៍ នៅត្រឹមឆ្នាំ២០៣០** ”។ ដូច្នេះយុទ្ធនាការប្រយុទ្ធនឹងជំងឺអេដស៍នៅកម្ពុជាគឺនៅតែជាអាទិភាពខ្ពស់របស់រាជរដ្ឋាភិបាល ដូចមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ដើម្បីកំណើន ការងារ សមធម៌ និង

ប្រសិទ្ធភាព “កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០” គឺរាជរដ្ឋាភិបាលនៅតែបង្ហាញការប្តេជ្ញាចិត្តដ៏មុឹងម៉ាត់ក្នុងការលប់បំបាត់ជំងឺអេដស៍ត្រឹមឆ្នាំ២០២៥ ។

៨. ឆ្លៀតក្នុងឱកាសចូលរួមអបអរសាទរ ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ ធ្នូ ២០១៨ នេះ ក្នុងនាមសម្តេចតេជោនាយករដ្ឋមន្ត្រី ខ្ញុំសូមផ្តល់សារមួយចំនួនជូនបងប្អូនជនរួមជាតិដូចខាងក្រោម ÷

**ទី១-** បន្តថែរក្សានូវចីរភាពភាពជោគជ័យ ដែលយើងទទួលបាននៅពេលនេះ និងបន្តឈានទៅសម្រេចឱ្យបាននូវការបញ្ចប់បញ្ហាអេដស៍នៅឆ្នាំ២០២៥ តាមរយៈការបន្តនូវការទទួលខុសត្រូវ និងចូលរួមឱ្យបានទូលំទូលាយ និងពហុវិស័យពីស្ថាប័នរាជរដ្ឋាភិបាល ស្ថាប័នឯកជន សង្គមស៊ីវិល ដៃគូអភិវឌ្ឍ បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ បណ្តាញអ្នកប្រឈមមុខខ្ពស់នឹងការចម្លងមេរោគអេដស៍ ព្រមទាំងប្រជាពលរដ្ឋទាំងអស់ ក្រោមការគ្រប់គ្រង ដឹកនាំ និងសម្របសម្រួលរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយឈរលើ **“គោលការណ៍បីមួយ”** គឺមានន័យថាស្ថាប័នដឹកនាំសម្របសម្រួលតែមួយ ផែនការយុទ្ធសាស្ត្រជាតិតែមួយ និងប្រព័ន្ធតាមដានវាយតម្លៃតែមួយ។

**ទី២-** សម្រាប់ការឆ្លើយតបនាពេលខាងមុខ កម្ពុជាមានផែនទីចង្អុលផ្លូវច្បាស់លាស់រួចទៅហើយ តាមរយៈគម្រោងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ លើកទីបួន ឆ្នាំ២០១៥ -២០២០។ ដូច្នេះអ្វីដែលត្រូវធ្វើ គឺការអនុវត្ត និងការប្តេជ្ញាចិត្តរបស់យើងទាំងអស់គ្នាឱ្យបានទ្វេដង នូវភាពជាម្ចាស់របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងស្ថាប័នពាក់ព័ន្ធក្នុងការបន្តនូវបេសកកម្មដ៏ថ្លៃថ្លានេះ លើការតាមដានការរាលដាលមេរោគអេដស៍ និងការឆ្លើយតបទៅនឹងជំងឺអេដស៍ ពិសេសគឺការគ្រប់គ្រង ការប្រើប្រាស់ធនធានឱ្យបានចំគោលដៅ និងអាទិភាព ដូចដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ លើកទីបួន ឆ្នាំ២០១៥ -២០២០ ដោយធានាឱ្យបាននូវការកសាងទំនុកចិត្ត និងអភិបាលកិច្ចល្អ ក្នុងការឆ្លើយតបរួមគ្នាទៅនឹងការរាលដាលមេរោគអេដស៍។

**ទី៣-** អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបន្តកិច្ចខិតខំប្រឹងប្រែងធ្វើការសិក្សាស្រាវជ្រាវស្វែងយល់ពីកត្តាគ្រោះថ្នាក់ថ្មីៗ ដែលអាចបង្កឱ្យមានការផ្ទុះឡើងនូវការចម្លងមេរោគអេដស៍ ដោយឈរលើគោលការណ៍គោរពសិទ្ធិមនុស្ស សមភាពយេនឌ័រ និងមិនទុកឱ្យនរណាម្នាក់មិនបានទទួលនូវសេវាបង្ការ ថែទាំ ព្យាបាល និងគាំទ្រដែលពួកគេត្រូវការនោះទេ។

**ទី៥-** ដើម្បីសម្រួលដល់ការឆ្លើយតបឱ្យបានទ្វេដង ទូលំទូលាយ គ្រប់ជ្រុងជ្រោយ និងទាន់ពេលវេលា ខ្ញុំសូមឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន រាជធានី-ខេត្ត ជាពិសេសឃុំ សង្កាត់ ត្រូវមានលទ្ធភាពកញ្ចប់ថវិកាសម្រាប់ឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍របស់ខ្លួន ផ្អែកទៅតាមគម្រោងផែនការយុទ្ធសាស្រ្តទូលំទូលាយ និងពហុវិស័យរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**ទី៦-** សកម្មជនប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ត្រូវយកឱកាសដ៏មានតម្លៃនៅថ្ងៃនេះ ដោយប្រើប្រាស់គ្រប់រូបភាព ធ្វើការផ្សព្វផ្សាយនូវព័ត៌មានថ្មីៗស្តីពីការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ព្រមទាំងលើកទឹកចិត្តប្រជាជនយើងឱ្យមានការចូលរួមកាន់តែខ្លាំងក្លាថែមទៀតក្នុងការបង្ការ ថែទាំ ព្យាបាល និងគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ជាបន្តទៀត។

**ទី៧-** ត្រូវយកចិត្តទុកដាក់គ្រប់គ្រងឱ្យបានទ្វេដង នូវការកាត់បន្ថយការចម្លងមេរោគអេដស៍ក្នុងចំណោមក្រុមប្រឈមមុខខ្ពស់នឹងការចម្លងមេរោគអេដស៍ ជាពិសេសក្រុមយុវវ័យ ក្រុមបុរសស្រឡាញ់បុរស ក្រុមអ្នកប្រើប្រាស់គ្រឿងញៀន ក្រុមចំណាកស្រុក ក្រុមបុគ្គលិកគ្រឹះស្ថានកម្សាន្តសប្បាយ ។ល។ តាមរយៈវិធានការ "**ឆាប់ធ្វើតេស្តឈាម ឆាប់ដឹង ឆាប់ព្យាបាល**" ។

**ទី៨-** ត្រូវស្វែងរកយុទ្ធសាស្រ្ត ផែនការអន្តរាគមន៍ដែលមានប្រសិទ្ធភាពខ្ពស់ក្នុងការឈានទៅសម្រេចឱ្យបាននូវការកាត់ផ្តាច់ទាំងស្រុង ការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និងលុបបំបាត់ទាំងស្រុងការរើសអើងមាក់ងាយទៅលើអ្នករងគ្រោះដោយសារជំងឺអេដស៍នៅត្រឹមឆ្នាំ ២០២០។

**ទី៩-** ត្រូវតែសម្រេចឱ្យបាននូវគោលដៅ ៩៥ ៩៥ ៩៥ នៅឆ្នាំ២០២៥ មានន័យថា ៩៥ % នៃអ្នកផ្ទុកមេរោគអេដស៍ បានយល់ដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន, ៩៥%នៃអ្នកដែលផ្ទុកមេរោគអេដស៍បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និង៩៥%នៃអ្នកដែលបានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ទទួលបានប្រសិទ្ធភាពខ្ពស់ក្នុងការកាត់បន្ថយចំនួនមេរោគអេដស៍នៅក្នុងខ្លួន និងធានាឱ្យបានថាប្រជាជនកម្ពុជាមានលទ្ធភាពប្រើប្រាស់សេវាបង្ការ សេវាប្រឹក្សា សេវាធ្វើតេស្តឈាម ព្រមទាំង សេវាព្យាបាលបានសមស្រប និងបានលឿនបំផុត។

**ទី១០-** ដើម្បីធានាចីរភាពក្នុងការងារប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួង ស្ថាប័ន រដ្ឋបាលមូលដ្ឋានដែលជាសមាជិកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ ត្រូវបញ្ជ្រាបការងារប្រយុទ្ធនឹងជំងឺអេដស៍ទៅក្នុងគោលនយោបាយ និងគម្រោងផែនការយុទ្ធសាស្រ្ត និងបញ្ចូលទៅក្នុងគម្រោងផែនការសកម្មភាពឱ្យបានគ្រប់ជ្រុងជ្រោយ។

**ទី១១-** ជំរុញ និងលើកទឹកចិត្តឱ្យប្រជាពលរដ្ឋប្រើប្រាស់ស្រោមអនាម័យ ឱ្យបានកាន់តែទូលំទូលាយព្រោះថា ស្រោមអនាម័យនៅតែជាមធ្យោបាយប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត ក្នុងការបង្ការការចម្លងមេរោគអេដស៍ មេរោគកាមរោគ និងការពន្យារកំណើត។ល។ ដូច្នេះស្រោមអនាម័យតែមួយមិនអាចប្រើប្រាស់ដើម្បីធ្វើជាភ័ស្តុតាងក្នុងការចោទប្រកាន់លើអំពើជួញដូរផ្លូវភេទបានទេ។

៩. ជាទីបញ្ចប់ ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាមសម្តេចតេជោនាយករដ្ឋមន្ត្រី ខ្ញុំព្រះករុណា ខ្ញុំ សូមប្រគេនពរ និងជូនពរគណៈអធិបតី សមាជិក សមាជិកានៃអង្គពិធី សូមទទួលបាននូវពុទ្ធពរទាំង ៥ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ និងសម្រេចបានជោគជ័យថ្មីៗបន្ថែមទៀតជូនជាតិមាតុភូមិ នៅឆ្នាំខាងមុខនេះ និងសូមប្រកាសជាឱឡារិកថា “**កម្ពុជាប្តេជ្ញាចិត្តទ្វេដងជាមួយអង្គការសហប្រជាជាតិ និងសកលលោកក្នុងការប្រើប្រាស់យុទ្ធសាស្ត្រ ដើម្បីឆ្ពោះទៅសម្រេចបាននូវគោលដៅ ៩៥ ៩៥ ៩៥ នៅឆ្នាំ ២០២៥**” ខាងមុខនេះ។

**សូមអរព្រះគុណ និងអរគុណ!**